សាលាកប័ត្រព័ត៌មាន ៖ កម្រងឯកសារសេរីភាពមូលដ្ឋាន ៖ ទីលានប្រជាធិបតេយ្យ

សេរីភាពមូលដ្ឋាន ៖ សេរីភាពបញ្ចេញមតិ និងប្រមូលផ្តុំ

រូបភាពរួម ៖ មានសេចក្តីព្រួយបារម្ភចំពោះការប្រើប្រាស់ខុសនូវ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ឆ្នាំ ២០០៩ ("ច្បាប់បាតុកម្ម") ដើម្បីធ្វើការគាបសង្កត់សេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំក្នុងព្រះរាជាណាចក្រ កម្ពុជា ("កម្ពុជា") ជាពិសេស គឺការប្រើអត្ថន័យដែលគួរឲ្យព្រួយបារម្ភដើម្បីដាក់កម្រិតលើការប្រមូលផ្តុំ ឬបាតុ-កម្មដោយសន្តិវិធីនៅក្នុង "ទីលានប្រជាធិបតេយ្យ" ដែលជាការរំលោភបំពានលើច្បាប់បាតុកម្ម និងសេរីភាព បញ្ចេញមតិ និងការប្រមូលផ្តុំដែលបានតម្កល់ក្នុងច្បាប់ជាតិ និងអន្តរជាតិ។

សេចក្តីផ្តើម

សាលាកប័ត្រព័ត៌មាននេះផ្តល់នូវទិដ្ឋភាពរួមនៃការប្រើប្រាស់ "ទីលានប្រជាធិបតេយ្យ" នៅកម្ពុជា – ដែលត្រូវបានដាក់បញ្ចូលទៅក្នុងសទ្ធានុក្រមប្រទេសកម្ពុជា និងនៅក្នុងការប្រើប្រាស់ដោយច្បាប់បាតុកម្ម – ជាពិសេស ការព្រួយបារម្ភថាទីលានប្រជាធិបតេយ្យនឹងត្រូវប្រើដើម្បីកំហិតសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំនៅកម្ពុជា។ សាលាកប័ត្រព័ត៌មាននេះគាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ("អង្គការ") ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

សេរីភាពមូលដ្ឋាន – ច្បាប់ជាតិ និងអន្តរជាតិ

សិទ្ធិនៃសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំគឺត្រូវបានការពារ និងលើកកម្ពស់នៅក្នុងច្បាប់កម្ពុជា។ មាត្រា៣៥ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ចែងថាប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយរបស់ប្រទេស។ មាត្រា៤១ ចែងថាប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវមានសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការប្រជុំ។ មាត្រា៣១ ចែងថាកម្ពុជាទទួលស្គាល់ និងគោរពសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស ដូច្នេះបានបញ្ចូលសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយទៅក្នុងច្បាប់ជាតិ។ មាត្រា១៩ នៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលពេលក្រោយមកកម្ពុជាយល់ព្រម និងផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩២ ចែងថាសិទ្ធិនៃសេរីភាពបញ្ចេញមតិគឺសម្រាប់មនុស្សគ្រប់គ្នា ចំណែកមាត្រា២០ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងមាត្រា២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ បានចែងអំពីសេរីភាពក្នុងការប្រមូលផ្តុំ។

ច្បាប់បាតុកម្ម និងទីលានប្រជាធិបតេយ្យ

ច្បាប់បាតុកម្មត្រូវបានអនុម័តកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩។ គោលបំណងនៃច្បាប់នេះ គឺដើម្បីធានានូវសេរីភាពបញ្ចេញមតិសម្រាប់ប្រជាពលរដ្ឋខ្មែរ តាមរយៈការប្រមូលផ្តុំដោយសន្តិវិធីប៉ុន្តែមិនត្រូវប្រើសិទ្ធិនេះដោយរំលោភបណ្តាលឲ្យប៉ះពាល់ដល់សិទ្ធិ សេរីភាព និងកិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ដ៏ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិ

នោះទេ។ វិសាលភាពនៃច្បាប់បាតុកម្មគ្របដណ្តប់រាល់ការប្រមូលផ្តុំ ឬបាតុកម្មទាំងអស់នៅកម្ពុជា លើកលែង យុទ្ធនាការបោះឆ្នោត ការប្រមូលផ្តុំដែលពាក់ព័ន្ធនឹងជម្លោះការងារ ក្បួនដង្ហែ ក្បួនដង្ហែសាកសព ការប្រមូលផ្តុំដទៃទៀតដែលបម្រើឲ្យគោលបំណងសាសនា សិល្បៈ វប្បធម៌ ទំនៀមទំលាប់ និងប្រពៃណីរបស់ប្រទេស និងសកម្មភាពការចែកចាយជាលក្ខណៈអប់រំដែលបម្រើដល់ផលប្រយោជន៍សង្គម។ ច្បាប់បាតុកម្មតម្រូវឲ្យបង្កើត "ទីលានប្រជាធិបតេយ្យ" ក្នុងរាជធានី ឬនៅតាមខេត្តនីមួយៗ។ ទីលានប្រជាធិបតេយ្យ គឺជាទីកន្លែង ដែលក្រុមបាតុករអាចធ្វើបាតុកម្មដោយសន្តិវិធីក្នុងលក្ខខណ្ឌដែលត្រូវផ្តល់ដំណឹង ១២ម៉ោងមុន ជំនួសឲ្យការផ្តល់ដំណឹង ៥ថ្ងៃមុនដែលតម្រូវដោយច្បាប់បាតុកម្មក្នុងការធ្វើបាតុកម្មជាទូទៅ។ ប៉ុន្តែ ច្បាប់បាតុកម្មកំណត់ចំនួនបាតុកររនៅក្នុងទីលានប្រជាធិបតេយ្យ ត្រឹមតែ ២០០នាក់ ខណៈពេលដែលការធ្វើបាតុកម្មទូទៅគ្មានការកំណត់ចំនួនបាតុកររនោះទេ។

ហានិភ័យនៃការអនុវត្ត – ទីលានប្រជាធិបតេយ្យ

ក្នុងពេលពង្រាងច្បាប់បាតុកម្ម ទីលានប្រជាធិបតេយ្យគ្មានគោលបំណងប្រើជាកន្លែងហាមឃាត់មិនឲ្យមានការប្រមូលផ្តុំដោយសន្តិវិធី និងធ្វើបាតុកម្មនៅទីសាធារណៈដទៃទៀតនោះទេ ផ្ទុយទៅវិញទីលាននោះនឹងត្រូវប្រើជាជម្រើសដើម្បីឲ្យមានការប្រមូលផ្តុំ ឬបាតុកម្មជាសាធារណៈដែលតម្រូវឲ្យមានការផ្តល់ដំណឹងក្នុងរយៈពេលខ្លីជូនដល់អាជ្ញាធរពាក់ព័ន្ធ។ ប៉ុន្តែ មានសេចក្តីព្រួយបារម្ភថាច្បាប់បាតុកម្ម នឹងត្រូវបានប្រើក្នុងគោលបំណងមិនត្រឹមត្រូវដែលកំណត់ដោយអាជ្ញាធរតម្រូវថារាល់ការប្រមូលផ្តុំ ឬបាតុកម្មទាំងអស់ត្រូវតែធ្វើឡើងក្នុងទីលានប្រជាធិបតេយ្យប៉ុណ្ណោះ។ ការប្រើប្រាស់ច្បាប់បាតុកម្មក្នុងលក្ខណៈបែបនោះ គឺបានរំលោភបំពានលើរដ្ឋធម្មនុញ្ញ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ព្រោះច្បាប់នេះបានបំបាត់សិទ្ធិនៃសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំ ៖ ក្រោមច្បាប់កម្ពុជាប្រជា-ពលរដ្ឋមិនគួរត្រូវបានរារាំងដោយការដាក់កំហិតទីតាំងនោះទេ។ សេចក្តីព្រួយបារម្ភមួយទៀតពាក់ព័ន្ធនឹងទីលានប្រជាធិបតេយ្យគឺថា ទីលាននេះអាចមានទីតាំងនៅកន្លែងដែលប្រជាពលរដ្ឋមួយចំនួនតូចអាចមើលឃើញ ឬបានឮអំពីការប្រមូលផ្តុំ ឬបាតុកម្មដោយសន្តិវិធីទាំងនោះ ដែលផ្ទុយនឹងគោលបំណងនៃការធ្វើបាតុកម្ម ឬការតវ៉ា គឺដើម្បីចង់បង្ហាញពីការព្រួយបារម្ភ និងបញ្ចេញគំនិតរបស់ពួកគេ គឺដើម្បីជះឥទ្ធិពលទៅដល់ថ្នាក់ដឹកនាំរដ្ឋាភិបាល អាជ្ញាធរ និងសាធារណជនទូទៅ។ ប្រជាពលរដ្ឋមានការភ្ជួញភ្ជែរថាទីលានប្រជាធិបតេយ្យរបស់រាជធានីភ្នំពេញ មានទីតាំងឆ្ងាយពីអគាររដ្ឋសភា និងអគាររដ្ឋាភិបាលដទៃទៀតដែលមានក្រុមមនុស្សដែល ការប្រមូលផ្តុំ និងបាតុកម្មដោយសន្តិវិធីមានបំណងជះឥទ្ធិពលទៅលើ មិនអាចបានឮ។ ចំណែកការឆ្លើយតបដែលទទួលបានគឺ ទីតាំងបែបនោះគឺអាចការពារការរំខានដល់ជីវភាពរស់នៅរបស់អ្នកបង្កើតច្បាប់ និងមន្ត្រីរដ្ឋាភិបាល។ ការរារាំងយ៉ាងធ្ងន់ធ្ងរមកលើសិទ្ធិនៃការប្រមូលផ្តុំដោយសន្តិវិធី ដូចជាកំហិតឲ្យបាតុកម្ម និងការតវ៉ាធ្វើឡើងនៅក្នុងទីកន្លែងមួយចំនួនដែលឆ្ងាយពីភ្នែករបស់អាជ្ញាធរថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ គឺជាការរំលោភបំពានមកលើសិទ្ធិនៃសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំយ៉ាងសម្បើម។ ការភ័យខ្លាចមួយទៀត ជាពិសេសគឺដោយសារតែទីលានប្រជាធិបតេយ្យមួយចំនួនធំមិនទាន់ត្រូវបាន បង្កើតនៅតាមថ្នាក់ខេត្តនៅឡើយ ដូចការពណ៌នាក្នុងច្បាប់បាតុកម្ម គឺថាកង្វះ

ខាតនៃទីលានប្រជាធិបតេយ្យ រួមជាមួយនឹងការកំហិតមិនឲ្យមានការប្រមូលផ្តុំនៅកន្លែងផ្សេងទៀត នឹងកាន់តែគាបសង្កត់លើសិទ្ធិដែលមាននៅក្នុងសេរីភាពជាមូលដ្ឋានទាំងនេះកាន់តែខ្លាំងឡើង។

សេចក្តីភ័យខ្លាចក្លាយជាការពិត

ក្នុងខែមិថុនា ឆ្នាំ២០១១ បុគ្គលិករបស់រោងចក្រមិថុនាត្រូវបានហាមឃាត់មិនឲ្យដើរជាក្បួនទៅកាន់ផ្ទះរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីស្វែងរកដំណោះស្រាយពាក់ព័ន្ធនឹងជម្លោះការងារ។ សហភាពសហជីពកម្ពុជា និងបុគ្គលិកចំនួន ៣៥០នាក់មកពីរោងចក្រក្នុងខណ្ឌសែនសុខដែលទាមទារឲ្យមានការផ្តល់សំណងឲ្យបានខ្ពស់ជាង ត្រូវបានអនុញ្ញាតឲ្យប្រមូលផ្តុំនៅក្នុងទីលានប្រជាធិបតេយ្យរបស់រាជធានីភ្នំពេញតែប៉ុណ្ណោះ។ ករណីនេះគឺជាឧទាហរណ៍ដែលអាជ្ញាធរកម្ពុជាបំបាត់នូវសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំរបស់ប្រជាពលរដ្ឋដោយរឹតត្បិតឲ្យប្រជាពលរដ្ឋអាចប្រើប្រាស់បានតែទីលានប្រជាធិបតេយ្យប៉ុណ្ណោះ។ ការពិត ក្នុងច្បាប់បាតុកម្ម មិនមែនត្រឹមតែអនុញ្ញាតឲ្យរាល់ការប្រមូលផ្តុំ ឬការតវ៉ាអាចធ្វើទៅបានដោយស្របច្បាប់នៅទីសាធារណៈណាៗដែលសមរម្យ ដែលមិនមែនជាទីលានប្រជាធិបតេយ្យនោះទេ ក៏ប៉ុន្តែបុគ្គលិករបស់រោងចក្រវាយនភណ្ឌមិថុនាចេញមកធ្វើបាតុកម្មគឺដោយសារតែជម្លោះការងារ ដែលមានន័យថាករណីនេះមិនស្ថិតនៅក្រោមវិសាលភាពរបស់ច្បាប់បាតុកម្ម ដែលបានបញ្ជាក់ថា គ្មានទំនាក់ទំនងរវាងការធ្វើបាតុកម្ម និងទីលានប្រជាធិបតេយ្យនោះទេ។

សេចក្តីសន្និដ្ឋាន

សិទ្ធិនៃសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំគឺត្រូវបានការពារដោយច្បាប់ជាតិ និងអន្តរជាតិ។ ក្នុងច្បាប់បាតុកម្ម ការបង្កើតទីលានប្រជាធិបតេយ្យមិនបានរំលោភបំពានដល់សិទ្ធិទាំងអស់នេះទេ ផ្ទុយទៅវិញ គឺបង្កើតនូវទីតាំងដែលអាចជាជម្រើសមួយក្នុងការបង្ហាញពីសេចក្តីព្រួយបារម្ភ ដែលកាតព្វកិច្ចក្នុងការផ្តល់ដំណឹងមិនសូវជាមានលក្ខណៈធ្ងន់ធ្ងរ។ ប៉ុន្តែ មានសេចក្តីព្រួយបារម្ភចំពោះរំលោភបំពាន ទាំងជាក់ស្តែង និងដែលអាចកើតមាន មកលើច្បាប់បាតុកម្ម ដោយអាជ្ញាធរថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដែលបានកំហិតសិទ្ធិនៃសេរីភាពបញ្ចេញមតិ និងការប្រមូលផ្តុំដោយដាក់កំណត់ថាការប្រមូលផ្តុំ ឬបាតុកម្មដោយសន្តិវិធីត្រូវតែធ្វើឡើងក្នុងទីលានប្រជាធិប-តេយ្យប៉ុណ្ណោះ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង លោក អ៊ូ វីរៈ (+៨៥៥ (0) ១២ ៤០ ៤០ ៥១) ឬអ៊ីម៉ែល ouvirak@cchrcambodia.org **ឬ លោក រ៉ូប៊ឺត ហ្វីនច៍ (+៨៥៥ (0) ៧៨ ៨០ ៩៩ ៦0) ឬអ៊ីម៉ែល** robert.finch@cchrcambodia.org

Cambodian Center for Human Rights